00250637

C9/4/3


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE


**សំណុំរឿងព្រហ្មទណ្ឌ លេខ:** ០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ១៣)

**ចំពោះមុខ:**
ចៅក្រម ប្រាក់ គឹមសាន ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម នីយ ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

**កាលបរិច្ឆេទ:** ១២ ធ្នូ ២០០៨

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 12/12/2008
ម៉ោង (Time/Heure): 15:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Fry

---

**សាធារណៈ**

# សេចក្តីសម្រេចលើសំណើចំពោះការបញ្ជាក់លើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ដែលប្តឹងប្រឆាំងនឹងដីកាសម្រេចអំពីការបន្តរយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្ន ដោយផ្អែកលើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះ

---

**ការិយាល័យសហព្រះរាជអាជ្ញា**
ជា លាង
Robert PETIT
យ៉ែត ចរិយា
William SMITH
តាន់ សេណារ៉ុង
Anees AHMED

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 15/12/2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Fry

**ជនត្រូវចោទ**
នួន ជា

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
ហុង គឹមសួន
ឡោ ជុនធី
នី ចាន់ធី
គង់ ពិសី
យុង ផានិត
គឹម ម៉េងឃី
Silke Studzinsky
Martine JACQUIN

**សហមេធាវីការពារក្តី**
សុន អរុណ
Michiel PESTMAN
Victor KOPPE

១. **អង្គបុរេជំនុំជម្រះ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា** (“**អវតក**”) កត់សម្គាល់ឃើញមាន “បណ្តឹងឧទ្ធរណ៍ប្រឆាំងចំពោះដីកាសម្រេច អំពីការបន្តថេរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្ន” ដែលបានដាក់ដោយ **នួន ជា** នៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០៨ (“បណ្តឹងឧទ្ធរណ៍”)។

២. អនុលោមតាមវិធាន ៧៧(៣)(ខ) នៃវិធានផ្ទៃក្នុង “បន្ទាប់ពីបានពិចារណាលើការយល់ឃើញរបស់ភាគី អង្គបុរេជំនុំជម្រះអាចសម្រេចលើលើបណ្តឹងឧទ្ធរណ៍ ឬពាក្យសុំ ដោយផ្អែកលើតែមូលដ្ឋាននៃសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់ភាគីតែប៉ុណ្ណោះ”។

៣. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា នៅក្នុង “សេចក្តីសន្និដ្ឋានតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់ **នួន ជា** ទៅនឹងការបន្តថេរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្ន” សហព្រះរាជអាជ្ញាបានសន្និដ្ឋានថា បណ្តឹងឧទ្ធរណ៍នេះ “គួរតែយកមកធ្វើការសម្រេច ដោយផ្អែកលើតែសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ។”[១]

៤. នៅថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០០៨ សហមេធាវីការពារក្តីបានជូនដំណឹងដល់អង្គបុរេជំនុំជម្រះក្នុងលក្ខណៈមិនផ្លូវការថា សវនាការដេញដោល មិនមានលក្ខណៈចាំបាច់ឡើយ។

៦. បន្ទាប់ពីធ្វើការពិចារណាលើការយល់ឃើញរបស់សហព្រះរាជអាជ្ញា និងសហមេធាវីការពារក្តីរបស់ជនត្រូវចោទ (“ភាគី”) អង្គបុរេជំនុំជម្រះយល់ឃើញថា បណ្តឹងឧទ្ធរណ៍នេះ ត្រូវយកមកធ្វើការសម្រេចដោយផ្អែកលើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់ភាគីតែប៉ុណ្ណោះ។

៦. អនុលោមតាមមាត្រា ៨(៤) នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅ អ.វ.ត.ក សំណើឆ្លើយតបចំពោះសារណា នឹងត្រូវអនុញ្ញាត ក្នុងករណីដែលមិនមានអំណះអំណាងដេញដោលដោយផ្ទាល់មាត់។[២]

---

[១] ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា ស្តីពីការបន្តថេរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០៨ C9/4/2 វាក្យខណ្ឌទី ៣។

[២] សេចក្តីណែនាំអនុវត្ត អ.វ.ត.ក/០១/២០០៧/វិសោធនកម្មលើកទី២។

PRETRIAL CHAMBER CHAMBRE PRÉLIMINAIRE

**ហេតុដូច្នេះអង្គបុរេជំនុំជម្រះសម្រេច និងណែនាំ:**

(១) បណ្តឹងឧទ្ធរណ៍នឹងធ្វើការសម្រេច ដោយផ្អែកលើសេចក្តីសន្និដ្ឋានតបរបស់ភាគីតែប៉ុណ្ណោះ។

(២) អនុញ្ញាតឱ្យជនត្រូវចោទដាក់សេចក្តីសន្និដ្ឋានតបទៅនឹងសេចក្តីសន្និដ្ឋានតបរបស់សហព្រះរាជអាជ្ញាក្នុងរយៈពេល ប្រាំ(៥)ថ្ងៃ គិតចាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីសម្រេចនេះ។

ភ្នំពេញ, ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០៨

**ប្រធានអង្គបុរេជំនុំជម្រះ**

ប្រាក់ គឹមសាន